ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០៣៨ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការពិនិត្យករណីសំណើសុំពង្រីកបន្ថែមទីតាំងដីទំហំ ១១ ១៧៧ ហិកតា របស់ក្រុមហ៊ុន សុខា អូតែល សម្រាប់គម្រោងអភិវឌ្ឍនៅឧទ្យានជាតិព្រះមុនីវង្ស "បូកគោ"

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្ដីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្ដីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងប្រកាសលេខ ៧៦ ដនស/ប្រក ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ១៩៩៩ ស្ដីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងតួនាទីរបស់បណ្ដាការិយាល័យក្រោមឱវាទ
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស ម្រេ ច

**ប្រការ១** ៖ បង្កើតគណៈកម្មការពិនិត្យករណីសំណើសុំពង្រីកបន្ថែមទីតាំងដីទំហំ ១១ ១៧៧ ហិកតារបស់ក្រុមហ៊ុន សុខា អូតែល សម្រាប់គម្រោងអភិវឌ្ឍនៅឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ដែលមានសមាសភាព ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ទេព ធន** | រដ្ឋលេខាធិការ | ប្រធាន |
| ២- | ឯកឧត្តម **ឡោ ជាវុធ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- | ឯកឧត្តម **សូខន ឫទ្ធីគុណ** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធាន |
| ៤- | ឯកឧត្តម **ឡុងប៉ុណ្ណា ស៊ីរីវត្ត** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៥- | ឯកឧត្តម **ជា មូរ៉ា** | រដ្ឋលេខាធិការទេសចរណ៍ | សមាជិក |
| ៦- | ឯកឧត្តម **ស្រ៊ុន ដារិទ្ធិ** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៧- | ឯកឧត្តម **នេត្រ ភ័ក្ត្រា** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- | ឯកឧត្តម **លី រស្មី** | រដ្ឋលេខាធិការ | សមាជិក |
| ៩- | ឯកឧត្តម **ជា វុទ្ធី** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចកម្ពុជា | សមាជិក |
| ១០- | ឯកឧត្តម **ហាច្យ សុតសំភារ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១- | ឯកឧត្តម **ស្ងួន សុផា** | អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ | សមាជិក |
| ១២- | ឯកឧត្តម **ម៉ៅ ធនិន** | អភិបាលនៃគណៈអភិបាលខេត្តកំពត | សមាជិក |
| ១៣- | ឯកឧត្តម **មាស ប៊ុនធឿន** | ទីប្រឹក្សាក្រសួង | សមាជិក |
| ១៤- | លោក **កែវ រ៉ូហេ្យ** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ១៥- | លោក **ហូ ចាន់ថា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់ | សមាជិក |
| ១៦- | លោក **អេ ប៊ុនធឿន** | អគ្គលេខាធិការរងអចិន្ត្រៃយ៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ១៧- | លោក **ស្រុខ ជុំ** | ប្រធាននាយកដ្ឋានបច្ចេកទេស | សមាជិក |
| ១៨- | លោក **ដាញ៉ូ សារី** | ប្រធានមន្ទីរ ដ.ន.ស.ស ខេត្តកំពត | សមាជិក |
| ១៩- | លោក **ព៉ៀម សុវណ្ណា** | ប្រធានការិយាល័យសិក្សា | សមាជិក |
| ២០- | លោក **ដាំ សុថា** | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ២១- | លោក **ថាត រដ្ឋា** | អនុប្រធានការិយាល័យកិច្ចការគតិយុត្ត | សមាជិក |
| ២២- | លោក **ម៉ាច ហ្វូ** | មន្ត្រី | សមាជិក |
| ២៣- | លោក **ធី ពិសិដ្ឋ** | មន្ត្រី | សមាជិក |

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ច ដូចខាងក្រោម÷

- ចុះពិនិត្យ សិក្សា និងវាយតម្លៃលម្អិតលើទីតាំងដីទំហំ ១១ ១១៧ ហិកតា ដែលក្រុមហ៊ុនបាន ស្នើសុំពង្រីកបន្ថែម
- ធ្វើរបាយការណ៍ ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់របស់ថ្នាក់ដឹកនាំក្រសួង។

**ប្រការ៣ :** គណៈកម្មការនេះ អាចប្រើប្រាស់មន្ត្រីក្រោមឱវាទក្រសួងឱ្យជួយការងារតាមការចាំបាច់។

**ប្រការ៤ :** នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ និង សាមីខ្លួនដូចមានរាយនាមក្នុងប្រការ ១ត្រូវអនុវត្តសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងបរិស្ថាន
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រដ្ឋបាលខេត្តកំពត
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ